# សេវាសម្រាប់ជនដែលគ្មានទីលំនៅ

## (រួមទាំងការវាយតម្លៃបឋមនិងការរៀបចំផែនការ)

សេវានេះអាចផ្តល់ការតស៊ូមតិ ពត៌មាននិងការបញ្ជូនចំពោះពលរដ្ឋរស់នៅក្នុងតំបន់ **Dandenong, Casey, Cardinia, Frankston** និង **Mornington Peninsula**។ សេវានេះរាប់បញ្ចូលទាំងការបញ្ជូនទៅសេវាមានវិបត្តិផ្នែកទីស្នាក់អាស្រ័យ សេវាជំនួយក្នុងការផ្លាស់ប្តូរនិងជម្រើសទីលំនៅរយៈពេលវែង ដោយរួមទាំងការជួលផ្ទះរដ្ឋនិងផ្ទះឯកជនផង។

មូលនិធិសម្រាប់ការរៀបចំទីលំនៅ **(HEF)** អាចមានជូនផងដែរសម្រាប់អ្នកជួលផ្ទះឯកជន ក្នុងការផ្តល់ជំនួយជាប្រាក់កាសដែលមានកម្រិត សម្រាប់ការជំពាក់ថ្លៃជួលផ្ទះ ឬការបង់ថ្លៃជួលផ្ទះមុនពេល ដើម្បីរក្សាទីលំនៅឬឲ្យមានទីលំនៅថ្មី។ ជំនួយពីសេវា **HEF** គឺអាចផ្តល់ជូនបាន ដោយអាស្រ័យទៅលើថវិកាជំនួយដែលមាន នឹងការវាយតម្លៃទៅលើសិទ្ធិទទួលជំនួយនេះ។ សេវានេះ ពុំមានសម្រាប់អ្នកជួលផ្ទះរដ្ឋនិងអ្នកជួលផ្ទះរដ្ឋរួមគ្នានោះទេ។

**DANDENONG** **9791 6111**
ពីម៉ោង **8.30** ព្រឹកដល់ម៉ោង **5.30** រសៀល ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ

**FRANKSTON/PENINSULA** **9770 2867**
ពីម៉ោង **9.30** ព្រឹកដល់ម៉ោង **4.30** រសៀល ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ

**PAKENHAM** **9703 0044**
ពីម៉ោង **9.30** ព្រឹកដល់ម៉ោង **4.30** រសៀល ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ

**NARRE WARREN** **9703 0044**
ពីម៉ោង **9.30** ព្រឹកដល់ម៉ោង **4.30** រសៀល ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ

**CRANBOURNE** **5990 6789**
ពីម៉ោង **9** ព្រឹកដល់ម៉ោង **4.30** រសៀល ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ

បើការិយាល័យដែលនៅជិតលោកអ្នកបំផុត មិនបើកទ្វារនៅថ្ងៃនិងពេលវេលាដែលលោកអ្នកត្រូវការជំនួយនោះទេ សូមទាក់ទងការិយាល័យនៅតំបន់ **Dandenong**។ សូមរំលឹកថាកម្មវិធីនេះមិនផ្តល់ជំនួយគាំពារនោះទេ។

# សេវាវិបត្តិអំពើហិង្សាក្នុងគ្រួសារ

សេវានេះបម្រើការបន្ថែមម៉ោងចំនួន **7** ថ្ងៃក្នុងមួយអាទិត្យ ហើយផ្តល់ជំនួយដល់ស្ត្រីនិងកុមារ ដែលគេចចេញពីអំពើហិង្សាក្នុងគ្រួសារ ទៅស្វែងរកជំនួយ ឱវាទ និងទីជម្រកក្នុងគ្រាមានវិបត្តិមួយរយៈកាលខ្លី។ សេវានេះផ្តល់នូវជម្រើសទទួលសេវាគាំពារដទៃមួយចំនួនទៀត។

*ពីម៉ោង **8.00** ព្រឹកដល់ម៉ោង **5.00** រសៀល* **9791 6111**
*ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ* *ឬ* **1800 357 397**

*ពីម៉ោង **5.00** រសៀលដល់ម៉ោង **10.00** យប់ ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ*
*ពីម៉ោង **10.00** ព្រឹកដល់ម៉ោង **5.00** រសៀល ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ*
*និងថ្ងៃបុណ្យឈប់សម្រាក* **0400 503 338**

# តើ WAYSS ជានរណា និងជាអ្វី?

**WAYSS Limited** ជាអង្គការសហគមន៍ ដែលបង្កើតឡើងដោយសារការច្របាច់បញ្ចូលគ្នានៃសមាគមសាជីវកម្មតូចៗមួយចំនួន។ សេវារបស់ **WAYSS Limited** ជាច្រើនបានប្រតិបត្តិការតាំងពីចុងទសវត្សរ៍ 1970 មកម្ល៉េះ។ សមាជិកភាពរបស់អង្គការនេះ រួមមានបុគ្គលដែលរស់នៅឬធ្វើការនៅក្នុងតំបន់ភាគអាគ្នេយ៍ជាយក្រុងមែលប៊ិន ហើយតាំងចិត្តគាំទ្រដល់ការផ្តល់សេវាដល់បណ្តាជនដែលប្រឈមមុខនឹងបញ្ហាទីលំនៅ។

គណៈកម្មការធ្វើការដោយស្ម័គ្រចិត្តមួយក្រុម គឺជាអ្នកគ្រប់គ្រងនិងត្រួតពិនិត្យកិច្ចប្រតិបត្តិការរបស់អង្គការ ហើយការប្រតិបត្តិរបស់អង្គការនេះមើលការខុសត្រូវដោយនាយកប្រតិបត្តិ។ **WAYSS Limited** ពុំមានសម្ពន្ធភាពសាសនាឬនយោបាយណាមួយឡើយ។

សេវាភាគច្រើនដែលផ្តល់ជូនដោយ **WAYSS Limited** គឺមានការឧបត្ថម្ភថវិកាពីក្រសួងផ្តល់សេវាដល់មនុស្សជាតិនៃរដ្ឋាភិបាលរដ្ឋវិកតូរីយ៉ា**(Victorian Government's Department of Human Services)** ក្រោមកម្មវិធីជំនួយគាំពារទីលំនៅ **(SAAP)** និងកម្មវិធីគ្រប់គ្រងការផ្លាស់ប្តូរទីលំនៅបណ្តោះអាសន្ន **(THM)**។

**WAYSS Limited** មានគោលបំណងផ្តល់ជូននូវសេវាដ៏ប្រសើរបំផុតទៅតាមលទ្ធភាពនិងធនធានដែលមាន។ បុគ្គលិកទាំងអស់បានទទួលការបណ្តុះបណ្តាលតាមវិជ្ជាជីវៈ និង/ឬ មានសញ្ញាបត្រកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងការងារ។ បើសិនជានៅពេលណាមួយលោកអ្នកចង់ពិភាក្សាអំពីបទដ្ឋាននៃការផ្តល់សេវា សូមស្នើសុំនិយាយ ជាមួយសមាជិកផ្នែកគ្រប់គ្រងណាម្នាក់ដែលរីករាយក្នុងការជួយលោកអ្នក។

រាល់ថវិកាជំនួយដែល **WAYSS Limited** បានទទួល គឺសម្រាប់ប្រើប្រាស់លើការផ្តល់សេវាដោយផ្ទាល់ ខាងផ្នែកសេវា គាំពារនិងទីលំនៅ។ អង្គការនេះមានការទទួលស្គាល់ពីការិយាល័យពន្ធដារអូស្ត្រាលីថាជាស្ថាប័នបម្រើសាធារណជនដោយមិនយកប្រាក់កម្រៃ **(not for profit)** ។ ដូច្នេះហើយរាល់ការបរិច្ចាគចាប់ពី$2 ឡើងទៅ គឺលោកអ្នកអាចទាមទារសុំមកវិញនៅពេលធ្វើបញ្ជីពន្ធដារប្រចាំឆ្នាំ។

### តើសេវាទាំងអស់មិនគិតថ្លៃទេឬ?

*រាល់សេវាផ្តល់ពត៌មាន ការបញ្ជូននឹងជំនួយគឺផ្តល់ជូនដោយឥតគិតថ្លៃឡើយ។ មូលនិធិសម្រាប់ការរៀបចំទីលំនៅជាទូទៅផ្តល់ជូនតាមបែបហិរញ្ញប្បទានដែលមិនតម្រូវឲ្យបង់សងវិញឡើយ នៅក្នុងករណីនៃការជំពាក់ថ្លៃជួលផ្ទះ ឬការបង់ថ្លៃជួលផ្ទះមុនពេល ក៏ប៉ុន្តែអាចផ្តល់ជាប្រាក់កម្ចីដោយមិនគិតការប្រាក់នៅក្នុងករណីដទៃទៀត។ ប្រសិនបើមានការផ្តល់ជូននូវជំនួយផ្លាស់ប្តូរទីលំនៅបណ្តោះអាសន្ន **(Transitional Housing)** វិញនោះ គឺវាអាស្រ័យទៅលើការពិនិត្យមើលប្រាក់ចំណូលនិងធនធានរបស់បុគ្គលនោះ ដោយមានការយកថ្លៃឈ្នួលផ្ទះ ដូចគ្នាទៅនឹងតម្លៃឈ្នួលផ្ទះរដ្ឋនៅក្នុងរដ្ឋវិកតូរីយ៉ាដែរ។*

### ហេតុអ្វីបានជាមិនមានអាសយដ្ឋាននៅលើខិតបណ្ណនេះ?

*ជាទូទៅ **WAYSS** មិនផ្តល់ជូនសេវាដែលអតិថិជនអាចទៅពឹងពាក់ដល់កន្លែងដោយពុំមានការឲ្យដឹងទុកជាមុននោះទេ តែយើងខ្ញុំស្វាគមន៍លោកអ្នកនៅគ្រប់ទីតាំង។ ដើម្បីចៀសវាងការរង់ចាំយូរ ការទូរស័ព្ទមកនិយាយជាមួយនឹងបុគ្គលិកជាមុនសិន គឺជាការមួយដ៏ប្រពៃ។ ប្រសិនបើត្រូវមានការណាត់ជួបណាមួយនោះ បុគ្គលិកនឹងពិភាក្សាពីជម្រើសទីកន្លែងដែលសមរម្យបំផុតសម្រាប់លោកអ្នក។*

DCN. 137/4

**WAYSS**
**LTD**
ABN 38 080 191 108

*Providing Housing & Support Services in the Community*

# ពត៌មានអំពីសេវានិងការទាក់ទង

ការិយាល័យដែលបានចុះឈ្មោះ៖
**294-300 Thomas Street**
**Dandenong Vic 3175**

ទូរស័ព្ទ៖ **(03) 9791 6111**
ទូរសារ៖ **(03) 9793 5078**
អ៊ីមែល៖ **info@wayssltd.org.au**
វិបសាយថ៍៖ **www.wayssltd.org.au**

**WAYSS** គឺជាស្ថាប័នដែលមានការចុះឈ្មោះត្រឹមត្រូវសម្រាប់ការផ្តល់ជំនួយផ្នែកទីលំនៅនិងជាសេវាដែលមានការទទួលស្គាល់ដើម្បីជួយជនដែលគ្មានទីលំនៅ។